**ក្រសួងពាណិជ្ជកម្ម**

លេខ ៣១៩៩ ព.ណ.ន.ជ.

ថ្ងៃអង្គារ ៤ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០២៣

## សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ អ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់ ជ្រាបថា រដ្ឋាភិបាលនៃចក្រភពអង់គ្លេសបានប្រកាសអំពីការផ្តល់នូវប្រព័ន្ធអនុគ្រោះពន្ធថ្មី UK's Developing Countries Trading Scheme (DCTS) ជំនួស UK's Generalized Scheme of Preference (GSP) ក្នុងគោលបំណងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ រួមទាំងប្រទេសអភិវឌ្ឍតិចតួចក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ។

បន្ថែមលើអត្រាពន្ធសូន្យ និងមិនកម្រិតបរិមាណ (duty-free & quota-free) ដែលប្រទេសអភិវឌ្ឍតិចតួចរួមទាំងប្រទេសកម្ពុជាធ្លាប់ទទួលបាន ប្រព័ន្ធអនុគ្រោះពន្ធថ្មីនេះ (DCTS) នឹងផ្តល់ភាពងាយស្រួលបន្ថែមទៀតតាមរយៈការធ្វើសេរីភាវូបនីយកម្មវិធានដើមកំណើតទំនិញ និងការធ្វើសាមញ្ញកម្មលើលក្ខខណ្ឌតម្រូវ ដែលក្នុងនោះបានអនុញ្ញាតឱ្យប្រើប្រាស់តម្លៃបន្ថែមក្នុងស្រុក (Local content) ត្រឹម ២៥% (តម្លៃវត្ថុធាតុដើមនាំចូលសម្រាប់ប្រើប្រាស់ (Non-originating content) រហូតដល់ ៧៥%) ឬការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធរហូតដល់៤ខ្ទង់ ទៅ៦ខ្ទង់។

ដើម្បីទទួលបានការអនុគ្រោះពន្ធពីចក្រភពអង់គ្លេស ផលិតករ ឬអ្នកនាំចេញទាំងអស់ ត្រូវអនុវត្តតាមវិធានដើមកំណើតទំនិញរបស់ចក្រភពអង់គ្លេស។ ចំពោះព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័រ https://www.gov.uk/government/publications/developing-countries-trading-scheme-dcts-new-policy-report/developing-countries-trading-scheme-government-policy-response ឬសូមទំនាក់ទំនងមន្ត្រី នៃនាយកដ្ឋាននាំចេញនាំចូល ដូចខាងក្រោម៖

១-លោក ជី សុថារិទ្ធ អនុប្រធាននាយកដ្ឋាននាំចេញនាំចូល

ទូរស័ព្ទលេខ៖ ០១៦ ៤៣២ ៤៤៤ អ៊ីមែល ៖ tharith.chy@gmail.com

២-លោកស្រី ម៉ក់ ច័ន្ទសុវណ្ណវល័ក្ខ ប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញនាំចូល

ទូរស័ព្ទលេខ៖ ០១២ ៦៩២ ០៨៤ អ៊ីមែល ៖ makchansovanvoleak@yahoo.com

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់ជ្រាបជាព័ត៌មាន។

សូមអរគុណ!